**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

ROYAL GROUP PHNOM PENH SEZ

លេខ: ០៧០/២២

# សេចក្តីជូនដំណឹង
# ស្តីពី
# កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ក្រុមហ៊ុន
# រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក (ស្ថិតក្នុងដំណើរការផ្លាស់ប្តូរជាផ្លូវការ)

**ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក (ស្ថិតក្នុងដំណើរការផ្លាស់ប្តូរជាផ្លូវការ)**មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតទាំងអស់មេត្តាជ្រាបថា កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ នឹងប្រព្រឹត្តិទៅនៅ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០២២ ដោយអនុលោមតាមការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុន កាលពីថ្ងៃទី១១ ខែ វិច្ឆិកា ឆ្នាំ ២០២២ ។ ការប្រជុំនេះនឹងត្រូវអនុលោមតាមគោលការណ៍ជំងឺកូវីដ-១៩ នៅកម្ពុជាតាមរយៈការហៅជាវីដេអូ។ ដូច្នេះការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនេះមានការកំណត់ដូចខាងក្រោម៖

១. កាលបរិច្ឆេទកំណត់ទុក (Recorded date): ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០២២
២. កាលបរិច្ឆេទកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក: ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០២២ វេលាម៉ោង ២:០០ ដល់ម៉ោង ៣:០០ រសៀល
៣. ទីកន្លែង: តាមរយៈការហៅជាវីដេអូ
៤. របៀបវារៈនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ៖
   - ការអនុម័តលើការបែងចែកភាគលាភ

ម្ចាស់ភាគហ៊ុនដែលមិនអាចចូលរួមក្នុងការប្រជុំអនឡាញបាន អាចមានអ្នកតំណាងណាម្នាក់ដើម្បីចូលរួម និងបោះឆ្នោតលើសេចក្តីសម្រេច (ប្រសិនបើមាន) ក៏ដូចជាយើងនឹងចែករំលែកប្រព័ន្ធនៃការហៅជាវីដេអូទៅកាន់អ្នកចុះឈ្មោះចូលរួម។

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលបានរៀបចំនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២២ នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិក lim.an@acledabank.com.kh huot.sophy@acledabank.com.kh និង op.rtp@acledabank.com.kh ពីធនាគារ អេស៊ីលីដា ភីអិលស៊ី ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់ ជារៀងរាល់ ម៉ោងធ្វើការ ចាប់ពី ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២២ ដល់ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២២។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្តីជូនដំណឹងខាងលើ សូមភាគហ៊ុនិកមេត្តាអញ្ជើញឆ្លើយតបតាមរយៈសារអេឡិចត្រូនិដើម្បីកញ្ជាក់ពីការចូលរួមជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណវិនិយោគិន និងឈ្មោះ ចាប់ពី ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២២ ដល់ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២២។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកធនាគារ អេស៊ីលីដា ភីអិលស៊ី តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម:

- អាសយដ្ឋាន ៖ ផ្ទះលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
- អ្នកទំនាក់ទំនង៖
  - លោក លឹម អាន ប្រធានផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
    អ៊ីម៉ែល: lim.an@acledabank.com.kh
  - លោក ហួត សុភី អនុប្រធានផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
    អ៊ីម៉ែល: huot.sophy@acledabank.com.kh
  - លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ បុគ្គលិកផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
    អ៊ីម៉ែល: op.rtp@acledabank.com.kh

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២២

**ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក**

**(ស្ថិតក្នុងដំណើរការផ្លាស់ប្តូរជាផ្លូវការ)**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
PHNOM PENH SEZ PLC.
KINGDOM OF CAMBODIA